ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ចាម

សាលក្រម

លេខៈ ៦៧ "ក" ចុះថ្ងៃទី០៦

ខែ មីនា ឆ្នាំ ២០២៤

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តកំពង់ចាម

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃព្រហស្បតិ៍ ៧រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧ ត្រូវនឹងថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤ លើសំណុំរឿងរដ្ឋប្បវេណី លេខៈ ១៣៣ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣៖

### ចៅក្រមទទួលបន្ទុក

ឯកឧត្តម [redacted] ជាប្រធានសាលាដំបូងខេត្តកំពង់ចាម

### ក្រឡាបញ្ជី

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម

-ដើមចោទឈ្មោះ [redacted] លីហ៊្សរ ភេទប្រុស កើតថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៩៦ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ [redacted]។

-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទៈ លោកស្រី [redacted]។

-សហចុងចម្លើយ៖

១-ឈ្មោះ [redacted] រតនាមុន្នី ភេទប្រុស កើតថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៧៩ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ មានទីលំនៅបច្ចុប្បន្ន [redacted]។

២-ឈ្មោះ [redacted] ដារ៉ាន់ ភេទស្រី កើតថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៨២ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ មានទីលំនៅបច្ចុប្បន្ន [redacted]។

-មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយៈ លោក [redacted]។

<u>ដែលមានកម្មវត្ថុបណ្តឹងៈ</u>

**ដើមចោទទាមទារ៖**

១-ឱ្យសហចុងចម្លើយសងប្រាក់កម្ចីមកឱ្យដើមចោទដូចខាងក្រោម៖

-ប្រាក់ដើមចំនួន ២០,០០០USD (ពីរម៉ឺនដុល្លារអាមេរិក)។



Scanned with CamScanner

ឃ-ចំណុចគ្មានវិវាទៈ

១-ប្រាក់ដើមចំនួន ២០,០០០$ (ពីរម៉ឺន)ដុល្លារអាមេរិក ?

២-ប្រាក់ប្រដាប់ក្តី ។

## សំអាងហេតុ

១-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានអះអាងដោយបញ្ជាក់ថា: នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ សហចុងចម្លើយបានមកសុំខ្ចីប្រាក់ពីដើមចោទចំនួន ២០,០០០USD (ពីរម៉ឺនដុល្លារអាមេរិក) ដោយគិតការប្រាក់ ២% (ពីរភាគរយ) ស្មើនឹង ៤០០USD (បួនរយដុល្លារអាមេរិក) ក្នុងមួយខែ តាមរយៈកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១។ នៅក្នុងអំឡុងពេលអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាខ្ចីប្រាក់នេះ សហចុងចម្លើយបានខកខានបង់ការប្រាក់ឱ្យមកដើមចោទអស់រយៈពេលចំនួន ១៧ខែមកហើយ គឺចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ រហូតមកដល់សព្វថ្ងៃ។ ក្រោយពីសហចុងចម្លើយខកខានបង់ការប្រាក់មក ដើមចោទបានទុកពេលវេលាឱ្យពួកគាត់ដើម្បីស្វែងរកប្រាក់ដើម និងការប្រាក់មកសងវិញ តែសហចុងចម្លើយពុំបានសងប្រាក់ដើម និងការប្រាក់មកឱ្យកូនក្តីខ្ញុំទេ ហើយថែមទាំងគេចវេសជាហូរហែរហូតមក ឃើញថាសហចុងចម្លើយពុំមានឆន្ទៈសងប្រាក់មកឱ្យដើមចោទនោះឡើយ ។

២-ដើមចោទទាមទារការប្រាក់ ២% (ពីរភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន ២០,០០០USD (ពីរម៉ឺនដុល្លារអាមេរិក) ដោយគិតចាប់ពីថ្ងៃខកខានមិនបានបង់ គឺថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃសង។ ដោយការប្រាក់នេះ ដើមចោទយកមានចំនួនលើសពីច្បាប់កំណត់ គប្បីតុលាការកំណត់ឱ្យសហចុងចម្លើយសងការប្រាក់ឱ្យទៅដើមចោទត្រឹម ១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ ដែលមានកំណត់ក្នុងច្បាប់ ។

៣-ការស្នើសុំរបស់ដើមចោទត្រង់ចំណុចទី២ នៃកម្មវត្ថុបណ្តឹងឃើញថា ៖ ក្នុងប្រការ៤ នៃកិច្ចសន្យាពុំបានបញ្ជាក់ថាត្រូវរឹបអូស ឬលក់ឡាយឡុងទ្រព្យបញ្ចាំទេ ដោយបានចែងក្នុងចំណុច(ខ)ថា ក្នុងករណីបង់ការប្រាក់យឺតយ៉ាវរហូតដល់ ៣ខែ អនុញ្ញាតឱ្យភាគី(ក) រឹបអូសយកផ្ទះដែលបានដាក់បញ្ចាំដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់ ប្រការនេះផ្ទុយនឹងច្បាប់ ព្រោះថា ម្ចាស់បំណុលមិនអាចក្លាយជាម្ចាស់កម្មសិទ្ធិបានទេ។ ក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំម្ចាស់បំណុល នៃការអនុវត្តអាចផ្តល់សញ្ញាណនៃទ្រព្យសម្បត្តិរបស់កូនបំណុលដែលត្រូវរឹបអូសលក់ឡាយឡុងក្នុងពាក្យស្នើសុំជូនតុលាការអនុវត្តតាមនីតិវិធីបាន។ ការស្នើសុំទាមទារឱ្យតុលាការសម្រេចអនុញ្ញាតឱ្យអនុវត្តប្រការ៤ នៃកិច្ចសន្យាចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ មិនត្រឹមត្រូវតាមច្បាប់ទេ ។

៤-ដើមចោទទាមទារសំណងខាតបង់ពេលវេលា និងសេវាកម្មមេធាវីចំនួន ១០,០០០USD (មួយម៉ឺនដុល្លារអាមេរិក) ព្រោះជាកំហុសរបស់សហចុងចម្លើយខកខានមិនបានបំពេញកាតព្វកិច្ចធ្វើឱ្យដំណើរការនីតិវិធីបណ្តឹងកើតឡើងនាំឱ្យខាតពេលវេលា, សេវាកម្មមេធាវី និងសេវាកម្មផ្សេងៗទៀត ព្រមទាំងធ្វើឱ្យប៉ះពាល់ផ្លូវចិត្ត ហេតុនេះសហចុងចម្លើយត្រូវទទួលខុសត្រូវលើករណីទាមទារនេះ តែការទាមទារនេះមានចំនួនច្រើនហួសពីព្យសនកម្ម គប្បីតុលាការពិចារណា និងសម្រេចតាមការសមរម្យនៃការខូចខាត ។

៥-ចុងចម្លើយបានទទួលស្គាល់ថាពិតជាបានជំពាក់ប្រាក់ដើមចោទចំនួន ២០,០០០USD (ពីរម៉ឺនដុល្លារអាមេរិក) ហើយសុំពន្យាពេលសងជា ០២ដំណាក់កាល និងសុំកុំឱ្យមានការអនុវត្តសាលក្រមជាបណ្តោះអាសន្ន ព្រោះប៉ះពាល់ដល់ផលប្រយោជន៍ធ្ងន់ធ្ងរ។ ការលើកឡើងនេះ ពុំមានហេតុផលសមស្របតាមច្បាប់ឡើយ គប្បីតុលាការមិនលើកយកមកពិចារណា និងសម្រេចឡើយ ។



Scanned with CamScanner

ប្រាកដមែន។ ក្នុងកិច្ចសន្យានេះអ្នកខ្ចីគឺមានតែឈ្មោះ [redacted] រតនាមុន្នី តែម្នាក់ទេ ឯឈ្មោះ [redacted] ដារ៉ាន់ គ្រាន់តែជាសាក្សីតែប៉ុណ្ណោះ។ ហេតុនេះសូមឱ្យដើមចោទប្ដឹងតែឈ្មោះ [redacted] រតនាមុន្នី តែម្នាក់ទៅ។ ក្នុងរឿងនេះចុងចម្លើយបានបង់ការប្រាក់ឱ្យដើមចោទរហូតមក ទើបតែមកដល់ឆ្នាំ២០២៣នេះ ជួបវិបត្តិសេដ្ឋកិច្ច ទើបគាត់អាក់ខានបង់រហូតមកដល់សព្វថ្ងៃនេះ។ នៅពេលនេះចុងចម្លើយគាត់នៅតែរក្សាចម្លើយដូចមានក្នុងសេចក្ដីថ្លែងការណ៍ត្រៀមលើកទី១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ ដដែល ហើយចុងចម្លើយនៅតែមានឆន្ទៈក្នុងការសងប្រាក់ឱ្យទៅដើមចោទដដែល តែគាត់សុំឱ្យដើមចោទអនុគ្រោះការទាមទារការប្រាក់ ទាមទារសំណង និងមិនឱ្យមានការអនុវត្តសាលក្រមជាបណ្ដោះអាសន្ន ព្រោះប៉ះពាល់ដល់ផលប្រយោជន៍គាត់ធ្ងន់ធ្ងរ ដោយសារតែឡៃឡុងលក់អចលនវត្ថុពុំបានតម្លៃពេញឡើយ ។

៤.១-មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយបានថ្លែងការណ៍ថា៖ ចុងចម្លើយទទួលស្គាល់ថា ពិតជាជំពាក់ប្រាក់ដើមចំនួន ២០,០០០$ (ពីរម៉ឺន)ដុល្លារអាមេរិក ពិតប្រាកដមែន ហើយប្រាក់នេះខ្លួនសុំសងជា ២ដំណាក់កាល បើដើមចោទយល់ព្រមសុំកំណត់ពេលសង តែការប្រាក់ ២% ក្នុង ១ខែ គឺដើមចោទយកលើសពីច្បាប់កំណត់ នៅពេលនេះសុំឱ្យដើមចោទយកតាមច្បាប់គឺ ១៨% ក្នុង ១ឆ្នាំ ។

៤.២-មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយបានថ្លែងការណ៍ថា៖ ចំពោះការស្នើសុំអនុវត្តគ្រង់ប្រការ៤ នៃកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ ដោយរឹបអូសអចលនវត្ថុដាក់បញ្ចាំលក់ឡាយឡុងនោះ ចុងចម្លើយសុំច្រានចោល ព្រោះកិច្ចសន្យាពុំមានកំណត់ការសងទេ ។

៤.៣-មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយបានថ្លែងការណ៍ថា៖ ចំពោះការទាមទារសំណងការខាតបង់ពេលវេលា និងសេវាមេធាវីចំនួន ២០,០០០$ (ពីរម៉ឺន)ដុល្លារអាមេរិកនោះ ចុងចម្លើយពុំមានលទ្ធភាពបង់ឱ្យទេ ការទាមទារនេះច្រើនលើសលប់ គឺសុំបង់ឱ្យនូវកំរិតទាបបំផុត ។

៤.៤-មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយបានថ្លែងការណ៍ថា៖ ចំពោះការស្នើសុំអនុវត្តសាលក្រមបណ្ដោះអាសន្ននោះ ចុងចម្លើយសុំច្រានចោល ព្រោះគាត់ក៏មានឆន្ទៈសងបំណុលឱ្យទៅដើមចោទដែរ គឺគាត់រិះរកវិធីធ្វើផ្សេងៗ ដើម្បីដាក់លក់ផ្ទះរបស់គាត់យកលុយសងឱ្យដើមចោទ បើមានការអនុវត្តឡាយឡុងទ្រព្យសម្បត្តិគាត់នោះ ធ្វើឱ្យខាតបង់ផលប្រយោជន៍របស់គាត់ធ្ងន់ធ្ងរបំផុត ។

៥-ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវការតវ៉ា

មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] បានថ្លែងការណ៍ថា ដើមចោទមិនឯកភាពយល់ព្រមតាមសំណូមពររបស់ចុងចម្លើយឡើយ គឺដើមចោទនៅតែទាមទារដូចខាងលើដដែល ។

**គ-ចំណុចវិវាទ៖**

១-តើសហចុងចម្លើយមានកាតព្វកិច្ចត្រូវសងការប្រាក់ចំនួន ២% ក្នុង ១ខែ ឱ្យដើមចោទតទៅទៀត ឬទេ?

២-តើការស្នើសុំអនុវត្តគ្រង់ប្រការ៤ នៃកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ ឱ្យរឹបអូសអចលនវត្ថុដាក់បញ្ចាំ ឬលក់ឡាយឡុង របស់ដើមចោទត្រឹមត្រូវតាមច្បាប់ ឬទេ ?

៣-តើសហចុងចម្លើយមានកាតព្វកិច្ចសងប្រាក់សំណងខាតបង់ពេលវេលា និងសេវាមេធាវីឱ្យដើមចោទ ឬទេ?

៤-តើការស្នើសុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន ត្រឹមត្រូវតាមច្បាប់ ឬទេ ?



Scanned with CamScanner

២-អង្គហេតុជាមូលហេតុនៃការទាមទារដោយភាគីដើមចោទ៖

២.១-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទថ្លែងការណ៍ថាៈ កូនក្តីខ្ញុំនៅតែសុំរក្សាការទាមទារ និងអង្គហេតុនៃការទាមទារដូចមាននៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ និងក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ និងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤ ទុកជាបានការដដែល ។

ព្រោះថា សហចុងចម្លើយបានមកសុំខ្ចីប្រាក់ពីកូនក្តីខ្ញុំចំនួន ២០,០០០USD (ពីរម៉ឺនដុល្លារអាមេរិក) ដោយគិតការប្រាក់ ២% (ពីរភាគរយ) ស្មើនឹង ៤០០USD (បួនរយដុល្លារអាមេរិក) ក្នុងមួយខែ តាមរយៈកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ ។

២.២-មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយបានអះអាងថា ការស្នើសុំឱ្យអនុវត្តគ្រង់ប្រការ៤ នៃកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ ដោយសុំឱ្យរឹបអូសអចលវត្ថុដាក់បញ្ចាំ ឬទាមទារឡាយឡុងនូវទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបញ្ចាំ ព្រោះនៅពេលចុងចម្លើយមកខ្ចីប្រាក់ពីកូនក្តីខ្ញុំ គឺបានដាក់បញ្ចាំនូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៣០៥០១០៧-០៥០២ ក្បាលដីលេខ ៥០២ ទំហំ ១១៦ម$^{2}$ ស្ថិតនៅភូមិមេម៉ាយ សង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម ។

២.៣-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានអះអាងថាៈ សហចុងចម្លើយខកខានមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្នុងអំឡុងពេលនៃកិច្ចសន្យាខ្ចីប្រាក់នេះ សហចុងចម្លើយបានខកខានបង់ការប្រាក់ឱ្យមកដើមចោទអស់រយៈពេល ១៧ខែមកហើយ ខានបង់ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ រហូតមកដល់សព្វថ្ងៃនេះ។ ក្រោយពីសហចុងចម្លើយខកខានបង់ការប្រាក់មក ដើមចោទបានទុកពេលវេលាឱ្យពួកគាត់ដើម្បីស្វែងរកប្រាក់ដើម និងការប្រាក់មកសងវិញ តែសហចុងចម្លើយពុំបានសងប្រាក់ដើម និងការប្រាក់មកឱ្យដើមចោទទេ ហើយថែមទាំងគេចវេសជាហូរហែរហូតមក ។

២.៤-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានអះអាងថាៈ ចំពោះការទាមទារសំណងជំងឺចិត្ត និងសេវាមេធាវីចំនួន ១០,០០០USD (មួយម៉ឺនដុល្លារអាមេរិក) របស់ដើមចោទគឺ សហចុងចម្លើយខកខានក្នុងការបង់ប្រាក់ជូនដើមចោទ និងការមិនបំពេញកាតព្វកិច្ចរបស់សហចុងចម្លើយដែលធ្វើឱ្យដើមចោទទទួលរងនូវការខាតបង់យ៉ាងខ្លាំង រួមទាំងការខាតបង់ពេលវេលា សេវាផ្នែកច្បាប់ និងសេវាមេធាវីនានាដើម្បីទាមទារប្រាក់ដែលជំពាក់ខាងលើ ។

២.៥-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានអះអាងថាៈ សហចុងចម្លើយត្រូវជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តីពីព្រោះវាជាកំហុសរបស់សហចុងចម្លើយក្នុងរឿងក្តីនេះ ។

៣-ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវការទាមទារ៖

មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] រតនាមុន្នី និងឈ្មោះ [redacted] ដារ៉ាន់ៈ បានថ្លែងការណ៍ថា ចុងចម្លើយទទួលស្គាល់មូលហេតុនៃការទាមទារលើចំណុចទី១ លើប្រាក់ដើម និងចំណុចទី៥ លើប្រាក់ប្រដាប់ក្តី និងចំណុចទាមទារក្រៅពីនេះមិនទទួលស្គាល់ទេ ។

៤-ការតវ៉ា ភាគីសហចុងចម្លើយឈ្មោះ [redacted] រតនាមុន្នី និងឈ្មោះ [redacted] ដារ៉ាន់៖

មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] រតនាមុន្នី និងឈ្មោះ [redacted] ដារ៉ាន់ បានអះអាងថាៈ នៅពេលនេះចុងចម្លើយឈ្មោះ [redacted] រតនាមុន្នី ទទួលស្គាល់ថា ពិតជាជំពាក់ប្រាក់ដើមចោទចំនួន ២០,០០០USD (ពីរម៉ឺនដុល្លារអាមេរិក) ដូចមានក្នុងកិច្ចសន្យាចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១



Scanned with CamScanner

-ការប្រាក់ចំនួន ២% (ពីរភាគរយ) ក្នុងមួយខែ ចាប់ពីមិនបានបង់ការប្រាក់រហូតមកដល់ពេលសង ។

២-ស្នើសុំអនុវត្តត្រង់ប្រការ៤ នៃកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ ចុះថ្ងៃទី១៨.០៦.២០២១ ដោយរឹបអូសអចលនវត្ថុដាក់បញ្ចាំ ឬលក់ឡៃឡុងនូវទ្រព្យដែលជាកម្មវត្ថុនៃការដាក់បញ្ចាំ ។

៣-ទាមទារឱ្យសហចុងចម្លើយសងសំណងការខាតបង់ពេលវេលា និងសេវាមេធាវីចំនួន ១០,០០០USD (មួយម៉ឺនដុល្លារអាមេរិក) ។

៤-ស្នើសុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន ។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

**ក-<u>ខ្លឹមសារសាលក្រមដែលទាមទារដោយភាគី៖</u>**

**សាលក្រមទាមទារឱ្យតុលាការចេញដោយភាគីដើមចោទ៖**

១-ឱ្យសហចុងចម្លើយសងប្រាក់កម្ចីមកឱ្យដើមចោទដូចខាងក្រោម៖

-ប្រាក់ដើមចំនួន ២០,០០០USD (ពីរម៉ឺនដុល្លារអាមេរិក) ។

-ការប្រាក់ចំនួន ២% (ពីរភាគរយ) ក្នុងមួយខែ ចាប់ពីមិនបានបង់ការប្រាក់រហូតមកដល់ពេលសង ។

២-ស្នើសុំអនុវត្តត្រង់ប្រការ៤ នៃកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ ចុះថ្ងៃទី១៨.០៦.២០២១ ដោយរឹបអូសអចលនវត្ថុដាក់បញ្ចាំ ឬលក់ឡៃឡុងនូវទ្រព្យដែលជាកម្មវត្ថុនៃការដាក់បញ្ចាំ ។

៣-ទាមទារឱ្យសហចុងចម្លើយសងសំណងការខាតបង់ពេលវេលា និងសេវាមេធាវីចំនួន ១០,០០០USD (មួយម៉ឺនដុល្លារអាមេរិក) ។

៤-ស្នើសុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន ។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

**ខ-<u>អង្គហេតុ និងចំណុចវិវាទ៖</u>**

១-សង្ខេបអំពីរឿងក្ដីៈ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ សហចុងចម្លើយបានមកសុំខ្ចីប្រាក់ពីដើមចោទចំនួន ២០,០០០USD (ពីរម៉ឺនដុល្លារអាមេរិក) ដោយគិតការប្រាក់ ២% (ពីរភាគរយ) ស្មើនឹង ៤០០ USD (បួនរយដុល្លារអាមេរិក) ក្នុងមួយខែ តាមរយៈកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ ២០២១។ នៅក្នុងអំឡុងពេលអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាខ្ចីប្រាក់នេះ សហចុងចម្លើយបានខកខានបង់ការប្រាក់ឱ្យមកដើមចោទអស់ចំនួន ១៧ខែមកហើយ។ គឺចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ រហូតដល់សព្វថ្ងៃ ក្រោយពីសហចុងចម្លើយខកខានបង់ការប្រាក់មក ដើមចោទបានទុកពេលវេលាឱ្យពួកគាត់ដើម្បីស្វែងរកប្រាក់ដើម និងការប្រាក់មកសងឱ្យដើមចោទវិញ តែសហចុងចម្លើយពុំបានសងប្រាក់ដើម និងការប្រាក់មកឱ្យដើមចោទទេ ហើយថែមទាំងគេចវេសជាហូរហែរហូតមក ដោយមើលឃើញថា សហចុងចម្លើយពុំមានឆន្ទៈសងប្រាក់មកឱ្យដើមចោទនោះ ទើបដើមចោទដាក់ពាក្យមកតុលាការដើម្បីធ្វើការទាមទារដូចខាងលើនេះ ។



Scanned with CamScanner

៦-ចុងចម្លើយទទួលស្គាល់ថាពិតជាបានជំពាក់ប្រាក់ដើមចោទចំនួន ២០,០០០USD (ពីរម៉ឺនដុល្លារអាមេរិក) មិនទាន់សងទៅដើមចោទប្រាកដមែន។ តាមបញ្ញត្តិមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការអាចប្រកាសឱ្យអនុវត្តសាលក្រមជាបណ្ដោះអាសន្នលើចំណុចទី១ នៃការទាមទាររបស់ដើមចោទបាន ។

៧-ជាកំហុសរបស់សហចុងចម្លើយមិនបានបំពេញកាតព្វកិច្ចសងប្រាក់ឱ្យដើមចោទ ធ្វើឱ្យដំណើរការនីតិវិធីបណ្ដឹងកើតឡើង ដូចនេះប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយឈ្មោះ [redacted] រតនាមុន្នី និងឈ្មោះ [redacted] ដារ៉ាន់ ។

## <u>សេចក្ដីសម្រេចបញ្ជាប់</u>

១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] រតនាមុន្នី និងឈ្មោះ [redacted] ដារ៉ាន់ សងប្រាក់ដើមចំនួន ២០,០០០USD (ពីរម៉ឺនដុល្លារអាមេរិក) ឱ្យទៅដើមចោទឈ្មោះ [redacted] លីហ្សួរ ។

២-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] រតនាមុន្នី និងឈ្មោះ [redacted] ដារ៉ាន់ សងការប្រាក់ចំនួន ១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ២០,០០០USD (ពីរម៉ឺនដុល្លារអាមេរិក) ដោយគិតចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ រហូតដល់សងប្រាក់គ្រប់ចំនួន ឱ្យទៅដើមចោទឈ្មោះ [redacted] លីហ្សួរ ការទាមទារលើសពីនេះច្រានចោល ។

៣-ច្រានចោលការស្នើសុំអនុវត្តត្រង់ប្រការ៤ នៃកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ ដោយរឹបអូសអចលនវត្ថុដាក់បញ្ចាំ ឬលក់ឡៃឡុងនូវទ្រព្យដែលជាកម្មវត្ថុនៃការដាក់បញ្ចាំ របស់ដើមចោទឈ្មោះ [redacted] លីហ្សួរ ។

៤-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] រតនាមុន្នី និងឈ្មោះ [redacted] ដារ៉ាន់ សងសំណងការខាតបង់ពេលវេលា និងសេវាមេធាវីចំនួន ៤,០០០$ (បួនពាន់) ដុល្លារអាមេរិក ការទាមទារលើសពីនេះ ច្រានចោល ។

៥-សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នលើចំណុចទី១ ។

៦-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយឈ្មោះ [redacted] រតនាមុន្នី និងឈ្មោះ [redacted] ដារ៉ាន់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

បានឃើញ

**ចៅក្រម**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កំពង់ចាម, ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner